ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

រាជរដ្ឋាភិបាលកម្ពុជា

លេខ : ១៣៥ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# ការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៣២០/៤២១ ចុះថ្ងៃទី៣០ ខែមីនា ឆ្នាំ២០២០ ស្តីពីការតែងតាំងនិងការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៥ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២០ អនក្រ.បក ចុះថ្ងៃទី៣០ ខែមេសា ឆ្នាំ១៩៩៦ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងនិងរដ្ឋលេខាធិការដ្ឋាន
- បានឃើញអនុក្រឹត្យលេខ ១១៤ អនក្រ.បក ចុះថ្ងៃទី៧ ខែកញ្ញា ឆ្នាំ២០១៥ ស្តីពីការកំណត់របនាសម្ព័ន្ធគ្រប់គ្រងនិងមុខតំណែងក្នុងរចនាសម្ព័ន្ធគ្រប់គ្រងនៃក្រសួង-ស្ថាប័នថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ១១ អនក្រ.បក ចុះថ្ងៃទី៣១ ខែមករា ឆ្នាំ២០១៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ខុទ្ទកាល័យនាយករដ្ឋមន្ត្រី ឧបនាយករដ្ឋមន្ត្រី ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី និងរដ្ឋលេខាធិការជាប្រធានស្ថាប័ន
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើតនិងបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីជានាប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការដឹកនាំ ការគ្រប់គ្រង និងការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២

## បេសកកម្ម តួនាទី ភារកិច្ច និងរចនាសម្ព័ន្ធ

**មាត្រា២.-**

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល បំពេញមុខងារជាសេនាធិការឱ្យក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើបេសកកម្មដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថលនៃព្រះរាជាណាចក្រកម្ពុជា ដោយឈរលើគោលការណ៍សេដ្ឋកិច្ចទីផ្សារនិងសមធម៌សង្គម អនុលោមតាមគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ ច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល។

**មាត្រា៣.-**

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ ផែនការ គម្រោង កម្មវិធី និងផែនការសកម្មភាពពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- ចូលរួមរៀបចំនិងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀត ពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- រៀបចំនិងអនុវត្តគោលការណ៍ណែនាំឬបទដ្ឋានបច្ចេកទេសនានាសំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- ចូលរួមស្រាវជ្រាវ វិភាគ តាមដាន និងវាយតម្លៃការវិវឌ្ឍនិងនិន្នាការសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍តំបន់និងសកល
- ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថលដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- ដឹកនាំ គ្រប់គ្រង និងអភិវឌ្ឍថ្នាលឌីជីថលគ្រឹះនិងថ្នាលសេដ្ឋកិច្ចឌីជីថល ជាគុណប្រយោជន៍ដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- ចូលរួមរៀបចំកិច្ចសន្យានិង/ឬកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍ជាតិ តំបន់ និងសកល
- ចូលរួមរៀបចំសេចក្តីព្រាងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ច្បាប់ហិរញ្ញវត្ថុកែតម្រូវ និងច្បាប់ទូទាត់ថវិកា
- កសាងភាពជាដៃគូ ព្រមទាំងធ្វើកិច្ចសហការនិងកិច្ចសហប្រតិបត្តិការសេដ្ឋកិច្ចឌីជីថល ក្នុងបរិការណ៍ជាតិ តំបន់ និងសកល និងជាមួយនឹងអង្គការអន្តរជាតិនិង/ឬដៃគូអភិវឌ្ឍ
- ដឹកនាំ សហការ និងសម្របសម្រួលការធ្វើសុខដុមនីយកម្មមុខងារសេដ្ឋកិច្ចឌីជីថល ដោយមានការចូលរួមពីក្រសួង-ស្ថាប័ននិងអង្គភាពពាក់ព័ន្ធ
- រៀបចំនិងលើកកម្ពស់ការអប់រំ ការបណ្តុះបណ្តាល និងការផ្សព្វផ្សាយពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធកម្មរបស់អគ្គនាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៤.-**

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មាននាយកដ្ឋានក្រោមឱវាទចំនួន ៣ (បី) ដូចខាងក្រោម៖

- នាយកដ្ឋានកិច្ចការទូទៅ
- នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល
- នាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល។

នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល មានការិយាល័យក្រោមឱវាទមួយចំនួនតាមការចាំបាច់។ ការរៀបចំនិងការប្រព្រឹត្តទៅរបស់ការិយាល័យក្រោមឱវាទនាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

អង្គការលេខរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវកំណត់ជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

**មាត្រា៥.-**

នាយកដ្ឋានកិច្ចការទូទៅ បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល លើការងាររដ្ឋបាល ហិរញ្ញវត្ថុ បុគ្គលិក ធនធានមនុស្ស ទ្រព្យសម្បត្តិរដ្ឋ បណ្តុះបណ្តាល និងផ្សព្វផ្សាយ ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- ជាលេខាធិការដ្ឋាន ច្រកចេញ-ចូល និងជាកន្លែងតម្កល់ឯកសារនិងលិខិតស្នាមរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- សម្របសម្រួលនិងបូកសរុបផែនការសកម្មភាពរួមរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- រៀបចំថវិកាសម្រាប់កិច្ចដំណើរការរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- គ្រប់គ្រងកិច្ចការរដ្ឋបាល ហិរញ្ញវត្ថុ និងបុគ្គលិករបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- សម្របសម្រួលការគ្រប់គ្រងធនធានមនុស្សរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- គ្រប់គ្រងទ្រព្យសម្បត្តិរដ្ឋនិងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- រៀបចំកិច្ចប្រជុំនិងរបាយការណ៍និងកំណត់ហេតុនៃកិច្ចប្រជុំ ព្រមទាំងទទួលបន្ទុកការងារពិធីការរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- ទំនាក់ទំនងជាមួយនឹងស្ថាប័នជាតិ ស្ថាប័នអន្តរជាតិ និងវិស័យឯកជន
- សម្របសម្រួលការអប់រំនិងការបណ្តុះបណ្តាលរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- ផ្សព្វផ្សាយជាសាធារណៈអំពីការរៀបចំ ការប្រព្រឹត្តទៅ និងវឌ្ឍនភាពការងាររបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- សហការ សម្របសម្រួល និងបូកសរុបលទ្ធផលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធកម្មរបស់នាយកដ្ឋានជំនាញផ្សេងទៀតប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធកម្មរបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីអគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល។

**មាត្រា៦.-**

នាយកដ្ឋានហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល លើការងារគ្រប់គ្រងនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធឌីជីថល ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- រៀបចំនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធថ្នាលឌីជីថលគ្រឹះ ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល

- រៀបចំនិងអភិវឌ្ឍហេដ្ឋារចនាសម្ព័ន្ធគ្រប់គ្រងទិន្នន័យសេដ្ឋកិច្ចឌីជីថល
- រៀបចំនិងសហការរៀបចំសន្តិសុខឌីជីថលលើហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល និងកម្មវិធីសេដ្ឋកិច្ចឌីជីថលដែលបានអភិវឌ្ឍ
- រៀបចំនិងអនុវត្តគោលការណ៍ណែនាំឬបទដ្ឋានបច្ចេកទេសនានាសំដៅគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- ចូលរួមស្រាវជ្រាវ វិភាគ តាមដាន និងវាយតម្លៃការវិវឌ្ឍនិងនិន្នាការពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍តំបន់និងសកល
- សហការនិងសម្របសម្រួលការធ្វើសុខដុមនីយកម្មមុខងារពាក់ព័ន្ធនឹងហេដ្ឋារចនាសម្ព័ន្ធសេដ្ឋកិច្ចឌីជីថល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធកម្មរបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីអគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល។

**មាត្រា៧.-**

នាយកដ្ឋានកម្មវិធីសេដ្ឋកិច្ចឌីជីថល បំពេញមុខងារជាសេនាធិការឱ្យអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថលលើការងារគ្រប់គ្រងនិងអភិវឌ្ឍផលិតផល សេវា គម្រោង និងកម្មវិធីសេដ្ឋកិច្ចឌីជីថល ដោយមានតួនាទីនិងភារកិច្ចដូចខាងក្រោម៖

- រៀបចំនិងអភិវឌ្ឍផលិតផល សេវា និងកម្មវិធី ដែលគាំទ្រដល់ការអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- រៀបចំ អភិវឌ្ឍ និងនវានុវត្តទិន្នន័យសេដ្ឋកិច្ចឌីជីថល
- ពិនិត្យនិងធ្វើអាទិភាវូបនីយកម្មផលិតផល សេវា គម្រោង និងកម្មវិធីគ្រប់គ្រងនិងអភិវឌ្ឍសេដ្ឋកិច្ចឌីជីថល
- ចូលរួមស្រាវជ្រាវ វិភាគ តាមដាន និងវាយតម្លៃការវិវឌ្ឍនិងនិន្នាការពាក់ព័ន្ធនឹងការគ្រប់គ្រងនិងការអភិវឌ្ឍផលិតផល សេវា គម្រោង និងកម្មវិធីសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍តំបន់និងសកល
- ធ្វើនិយ័តកម្មសកម្មភាពសេដ្ឋកិច្ចឌីជីថលថ្មី
- តាមដាន ត្រួតពិនិត្យ និងវាយតម្លៃប្រសិទ្ធភាពនិងសក្តិសិទ្ធិភាពនៃការអនុវត្តគម្រោងនិងកម្មវិធីសេដ្ឋកិច្ចឌីជីថល
- សហការនិងសម្របសម្រួលការធ្វើសុខដុមនីយកម្មមុខងារពាក់ព័ន្ធនឹងផលិតផល សេវា គម្រោង និងកម្មវិធីសេដ្ឋកិច្ចឌីជីថល
- ចូលរួមរៀបចំនិងអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការអភិវឌ្ឍវិស័យនិងផែនការអភិវឌ្ឍស្ថាប័នពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- ចូលរួមរៀបចំនិងអនុវត្តច្បាប់និងលិខិតបទដ្ឋានគតិយុត្តផ្សេងទៀតពាក់ព័ន្ធនឹងសេដ្ឋកិច្ចឌីជីថល
- ចូលរួមរៀបចំកិច្ចសន្យានិង/ឬកិច្ចព្រមព្រៀងសេដ្ឋកិច្ចឌីជីថលក្នុងបរិការណ៍ជាតិ តំបន់ និងសកល
- រៀបចំរបាយការណ៍វឌ្ឍនភាពការងារនិងសមិទ្ធកម្មរបស់នាយកដ្ឋានប្រចាំខែ ត្រីមាស ឆមាស និងឆ្នាំ
- បំពេញតួនាទីនិងភារកិច្ចផ្សេងទៀតតាមការប្រគល់ជូនពីអគ្គនាយកនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល។

**មាត្រា៨.-**

អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវដឹកនាំដោយអគ្គនាយក១(មួយ)រូប អមដោយអគ្គនាយករងមួយ

ចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

នាយកដ្ឋាននីមួយៗនៃអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល ត្រូវដឹកនាំដោយប្រធាននាយកដ្ឋាន១(មួយ) រូប អមដោយអនុប្រធាននាយកដ្ឋានមួយចំនួន អនុលោមតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

## ជំពូកទី៣
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

អនុក្រឹត្យនេះត្រូវបំពេញបន្ថែមអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងមុខងារសាធារណៈ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៥កើត ខែបឋមាសាឍ ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២២ ខែមិថុនា ឆ្នាំ២០២៣

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១០
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ

**នៃអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០២៣**

**ស្តីពីការបង្កើតនិងការបំពេញបន្ថែមអគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល**

**ឱ្យស្ថិតនៅក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

## អង្គការលេខរបស់អគ្គនាយកដ្ឋានសេដ្ឋកិច្ចឌីជីថល

